គ.ជ.ប

# ព្រឹត្តិបត្រ

## គោលនយោបាយរបស់គណបក្សនយោបាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ចេញផ្សាយថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ លេខ ១

# ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

**ថ្ងៃបោះឆ្នោត ៖ នៅថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២**

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ (Tel) : (+855) 23 235 271

អ៊ីម៉ែល(Email): info@nec.gov.kh

Website: nec.gov.kh, voterlist.nec.gov.kh

Facebook/Youtube: National Election Committee

NEC KH (App)

# ការគូសសញ្ញាគាំទ្រគណបក្សលើសន្លឹកឆ្នោត

១ លោកអ្នកត្រូវគូសសញ្ញាណាមួយ ដូចខាងក្រោម៖

✓ ឬ X ឬ + ឬ – ឬ / ឬ \ ឬ V ឬ U ឬ ∩ ឬ 0 ( ឬ ) ឬ ~ ជាដើម ឬគូសសញ្ញាណាដែលគេមិនអាចស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត

២ សន្លឹកឆ្នោតដែលមិនអាចយកជាការបាន មានដូចជា៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតជាដើម

៣ គ.ជ.ប សូមលើកទឹកចិត្តឱ្យគូសសញ្ញាដូចខាងក្រោម៖

✓

# មាតិកា

ទំព័រ


- គណបក្សរស្មីខេមរា ........................................ ១
- គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ........................................ ២
- គណបក្ស ខ្មែររួបរួមជាតិ ........................................ ៣
- គណបក្សឆន្ទៈខ្មែរ ........................................ ៤
- គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា ........................................ ៥
- គណបក្សឯកភាពជាតិខ្មែរ ........................................ ៦
- គណបក្សខ្មែរតែមួយ ........................................ ៧
- គណបក្សយុវជនកម្ពុជា ........................................ ៨
- គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ........................................ ៩
- គណបក្សកែទម្រង់កម្ពុជា ........................................ ១០
- គណបក្សកម្ពុជានិយម ........................................ ១១
- គណបក្សសញ្ជាតិកម្ពុជា ........................................ ១២
- គណបក្សហ្វ៊ុនស៊ិនប៉ិច ........................................ ១៣
- គណបក្សប្រជាជនកម្ពុជា ........................................ ១៤
- គណបក្សខ្មែរស្រឡាញ់ជាតិ ........................................ ១៥
- គណបក្ស ភ្លើងទៀន ........................................ ១៦
- គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ........................................ ១៧

# គណបក្សរស្មីខេមរា

**REAKSMEY KHEMARA PARTY**

**សច្ចៈ ការពារ យុត្តិធម៌ អភិវឌ្ឍន៍**

## គណបក្សរស្មីខេមរា បានដាក់ចេញនូវគោលនយោបាយទាំង៦ចំនុច ដើម្បីគ្រប់គ្រងមូលដ្ឋានរួមមាន៖

១/ គណបក្សរស្មីខេមរា៖ ជាអ្នកបម្រើពលរដ្ឋ ធ្វើតាមឆន្ទៈពលរដ្ឋ ពលរដ្ឋជាម្ចាស់អំណាច ។

២/ រៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ៖ កសាងវត្តអារាម សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ និងជួសជុលផ្លូវថ្នល់ដែលខូចកន្លងមក ព្រមទាំងរៀបចំប្រព័ន្ធលូនៅតាមភូមិនីមួយៗ ប្រព័ន្ធធារាសាស្ត្រ ប្រឡាយបង្ហៀរទឹកស្រោចស្រង់ស្រែចំការ នៅតាមមូលដ្ឋានដើម្បីងាយស្រួលដល់ការបង្កបង្កើនផលរបស់ប្រជាពលរដ្ឋ ។

៣/ សេវាសុខភាពសាធារណៈ៖ មណ្ឌលសុខភាពត្រូវមានគ្រូពេទ្យនៅប្រចាំការព្រមទាំងមានថ្នាំគ្រប់គ្រាន់ និងឡានពេទ្យសម្រាប់ដឹកជញ្ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ពិនិត្យនិងព្យាបាលស្ត្រីមានផ្ទៃពោះដោយឥតគិតថ្លៃ។

៤/ រៀបចំសណ្តាប់ធ្នាប់សាធារណៈ ៖ សន្តិសុខនៅក្នុងមូលដ្ឋាន ត្រូវបំបាត់គ្រឿងញៀន ចោរកម្ម និងក្មេងទំនើង ល្បែងស៊ីសងផ្សេងៗ ព្រមទាំងរៀបចំវេទិកាសន្តិសុខភូមិ និងបង្កើតមូលនិធិនគរបាលល្អ។

៥/ កិច្ចការងាររដ្ឋបាលសាធារណៈ ៖ មន្ត្រីត្រូវបម្រើប្រជាពលរដ្ឋឱ្យរហ័សទាន់ពេល មិនពុករលួយ មិនរើសអើង មិនប្រកាន់បក្ខពួក មានសុជីវធម៌ល្អទៅកាន់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងមិនតម្រូវឱ្យទាមទារ ឬត្រូវបង់ថ្លៃលើឯកសារលើសការកំណត់។

៦/ លើកកម្ពស់ គាំពារកុមារ និងស្ត្រី៖ លុបបំបាត់អំពើហិង្សាមកលើកុមារ និងស្ត្រីភេទ ព្រមទាំងឱ្យស្ត្រីចូលរួមកិច្ចការសង្គមឱ្យបានច្រើនដូចបុរសដែរ ។

អាស្រ័យហេតុនេះសូម ពុកម៉ែ អ៊ំប្រុសអ៊ំស្រី ពូមីង បងប្រុសបងស្រី ប្អូនប្រុសប្អូនស្រីជាទីស្រឡាញ់ដែលមានជំនឿជឿជាក់ និងគាំទ្រគោលនយោបាយខាងលើនេះ សូមបោះឆ្នោតជូន គណបក្សរស្មីខេមរា ដែលមានរូបដើមត្នោតប្រាំដើម និងព្រះអាទិត្យជាសញ្ញាសម្គាល់។

| | | |
|---|---|---|
| | **គណបក្សរស្មីខេមរា**<br>**គ.រ.ខ** | ✓ |

**ស្ម័គ្រចិត្ត ប្តេជ្ញា បូជាដើម្បីជាតិ**

## គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គោលការណ៍ ៧ ចំណុចសង្ខេបជាអាទិភាព សម្រាប់ការចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ២០២២

គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យក៏ដូចជាប្រជាពលរដ្ឋខ្មែរជាទូទៅផងដែរ គឺមានបំណងប្រាថ្នាចង់ឃើញមានការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខណ្ឌឃុំ-សង្កាត់ឱ្យមានប្រសិទ្ធភាពជាវិជ្ជមាន ។ គោលការណ៍៧ ចំណុចសង្ខេបជាអាទិភាព ត្រូវបានបកស្រាយលម្អិតអំពីតួនាទីបម្រើកិច្ចការមូលដ្ឋានមានដូចតទៅ ៖

### ១. ជីវភាព

- រៀបចំផែនការ និងលើកគម្រោងផ្សេងៗដើម្បីជំរុញឱ្យមានការអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច មូលដ្ឋានដូចជា៖ សិប្បកម្ម ការបង្កើតការងារ និងរកទីផ្សារសម្រាប់ផលិតផលរបស់ខ្មែរ ក្នុងទិសដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមគ្នានោះដែរកាត់បន្ថយភាពក្រីក្រ ហើយមិនឱ្យប្រជាពលរដ្ឋណាម្នាក់ ស្លាប់ដោយអត់បាយនៅក្នុងឃុំរបស់យើង។

### ២. សុខភាព

- កសាងហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាល ដូចជាមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋឱ្យទាន់ពេលវេលា។ មិនឱ្យប្រជាពលរដ្ឋណាម្នាក់ស្លាប់ដោយគ្មានពេទ្យព្យាបាលនៅក្នុងឃុំរបស់យើង។ គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យមានគម្រោងសាងសង់បច្ឆាមួយ សមរម្យសម្រាប់បូជាសព ដោយសហការជាមួយ ពុទ្ធបរិស័ទជើងវត្ត នៅក្នុងឃុំរបស់យើង។ ក៏មានគម្រោងផងដែលសម្រាប់ជួយបូជាសពអ្នកដែលគ្មានញាតិសន្តាន និងក្រុមគ្រួសារ។

### ៣. សុវត្ថិភាព

- ធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន ត្រូវកម្ទេចឱ្យអស់នូវសំបុកចោរ សំបុកគ្រឿងញៀន និងសំបុកល្បែងស៊ីសងខុសច្បាប់ និងបំបាត់និទណ្ឌភាព។

### ៤. អភិបាលកិច្ចល្អ និងសេវាសាធារណៈ

- ចាត់ចែងឱ្យមាន គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ក្នុងការផ្តល់សេវាសាធារណៈ ហើយនឹងលុបបំបាត់វប្បធម៌រើសអើងប្រកាន់បក្ខពួក និងបុរេនិច្ច័យ។ បំបាត់អំពើពុករលួយក្នុងគ្រប់រូបភាព ។

### ៥. ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន

- កែលម្អភូមិឃុំឱ្យមានសោភ័ណភាព អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់មូលដ្ឋានរួមមាន ផ្លូវថ្នល់ ផ្លូវលំ លូបង្ហូរ ប្រឡាយធារាសាស្ត្រ និងអាងស្តុកទឹកកខ្វក់ គោមអគ្គិសនីបំភ្លឺផ្លូវសាធារណៈ ហើយនឹងថែទាំរក្សាការពារសម្បត្តិសាធារណៈដូចជា ៖ សាលារៀន មណ្ឌល សុខភាព។ល។និង ។ល។... រៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់កែលម្អជីវិតប្រចាំថ្ងៃ និងសុខភាព ដូចជា សួនលំហែកាយ សាលាបុណ្យ ឬសាលប្រជុំ ដើម្បីឆ្លើយតបសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលអាចទទួលមហាជនចំណុះច្រើនបាន។ បង្កើតឱ្យមានកាតព្វកិច្ចសង្គមក្នុងមូលដ្ឋាន៖ សហការ និងដាក់វេនគ្នាដោយស្ម័គ្រចិត្តក្នុងការសម្អាត និងកែលម្អបរិស្ថានភូមិ ឃុំ បង្កលក្ខណៈឱ្យមានការជួយគ្នាទៅវិញទៅមកក្នុងជិវិតប្រចាំថ្ងៃតាមរយៈការប្រវាស់ ឬ ការបង្កើតជាសហករណ៍ជាដើម ។

### ៦. វេទិកាសាធារណៈ

- ធ្វើកិច្ចប្រតិបត្តិគណនេយ្យភាពសង្គម ដោយពង្រឹងទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋ និងចាត់ចែងឱ្យមានជាវេទិកាសាធារណៈក្នុងចន្លោះរយៈពេលបីខែម្តង ដើម្បីប្រមូលយកយោបល់ និង សំណើរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

### ៧. ការអប់រំ សិក្សារៀនសូត្រ សិល្បៈ និងកីឡា

-បង្កលក្ខណៈឲ្យមានការចូលរួមរបស់យុវជន និងស្រ្តីភេទ ក្នុងគ្រប់គម្រោងអភិវឌ្ឍន៍ភូមិ-ឃុំ ជាពិសេស ការអប់រំ ដើម្បីការពារវប្បធម៌ជាតិ ទំនៀមទម្លាប់ប្រពៃណីខ្មែរ ទាំងផ្នែកអាណាចក្រ និងទាំងផ្នែកសាសនាចក្រ និងការហ្វឹកហាត់លើមុខវិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ទីផ្សារការងារ។ ជាពិសេសការអភិវឌ្ឍន៍គ្រប់វិស័យកីឡា រកទីកន្លែងសមស្របសម្រាប់ការបង្ហាត់ និងហ្វឹកហ្វឺន។

រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ៕

# គណបក្សខ្មែររួបរួមជាតិ

## ឯករាជ្យ សន្តិភាព យុត្តិធម៌

គណបក្សខ្មែររួបរួមជាតិ

ខ.រ.ជ

## គោលនយោបាយមូលដ្ឋាន

**១. ភូមិ ឃុំ សុខសាន្ត ៖** បង្កើនការអនុវត្តនិងទប់ស្កាត់អំពើចោរកម្ម ក្មេងទំនើង អំពើអសីលធម៌សង្គម ហិង្សាក្នុងគ្រួសារ ការចរាចរ និងសេពគ្រឿងញៀន។

**២. ភូមិ ឃុំ ស្អាតស្អំ ៖** គ្មានការរើសអើង បក្សពួកនិយម គ្រួសារនិយម គ្មានអំពើពុករលួយ និងគ្មានការយកកម្រៃសេវាក្រៅផ្លូវការលើសេវាសាធារណៈគ្រប់ប្រភេទ។

**៣. ភូមិ ឃុំ រុងរឿង ៖** បង្កើនសេដ្ឋកិច្ចគ្រួសារឲ្យបានធូរធារ តាមរយៈការជំរុញផលិតភាពកសិកម្មទំនើបនិងបច្ចេកទេសថ្មី ធានាតម្លៃកសិផលស្របតាមទីផ្សារ និងបង្កើនការងារថ្មីក្នុងមូលដ្ឋាន។

គណបក្សខ្មែររួបរួមជាតិ

ខ.រ.ជ

១

# គោលនយោបាយអាទិភាព ៧ ចំណុច

## ១. ការកែទម្រង់ប្រព័ន្ធការងារឃុំ-សង្កាត់

- លុបបំបាត់អំពើពុករលួយ បក្សពួកនិយម និងការបំពានអំណាច
- បង្កើតវប្បធម៌ដឹកនាំថ្មីក្នុងឃុំ-សង្កាត់
- បង្កើតសេវាគាំទ្រផ្នែកច្បាប់ជូនប្រជាពលរដ្ឋ
- ធានាផ្តល់សេវា បម្រើ ការពារ ស្អាតស្អំ ទាន់ចិត្តនិងប្រសិទ្ធភាពខ្ពស់
- មានតម្លាភាពពីប្រភពថវិការដ្ឋ សប្បុរសជន កម្រៃស្របច្បាប់ និងគម្រោងអភិវឌ្ឍនានា
- ឃុំសង្កាត់ សុវត្ថិភាព គ្មានគ្រឿងញៀន គ្មានចោរកម្ម គ្មានល្បែងពាលា គ្មានអំពើហិង្សា។

## ២. គោលនយោបាយដីធ្លី

- ធានាការពារដីកម្មសិទ្ធិស្របច្បាប់ និងដីសហគមន៍របស់ប្រជាពលរដ្ឋ
- លុបបំបាត់វិវាទដីធ្លី និងការទន្ទ្រានដីធ្លីក្នុងឃុំ-សង្កាត់
- គ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានសង្គមកិច្ច។

## ៣. គោលនយោបាយកសិកម្ម និងតម្លៃកសិផល

- ផ្សារភ្ជាប់កសិករទៅនឹងទីផ្សារ
- ផ្តល់ជូនគ្រាប់ពូជ និងដីកសិកម្មដល់ប្រជាពលរដ្ឋខ្វះខាត។
- ពិនិត្យផ្តល់ដីសម្បទានកសិកម្ម ដើម្បីធ្វើកសិកម្មសម្រាប់អ្នកខ្វះដី/កាត់បន្ថយចំណាកស្រុក
- បណ្តុះបណ្តាលសមត្ថភាពក្នុងការគ្រប់គ្រងថវិកា/ប្រាក់កម្ចី។

## ៤. គោលនយោបាយអប់រំ

- ឃុំមួយ សាលាមត្តេយ្យមួយ (សម្រាលបន្ទុកអាណាព្យាបាល បណ្តុះថ្នាលធនធានមនុស្ស)
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈដោយឥតគិតថ្លៃ។

## ៥. គោលនយោបាយបង្កើតការងារនៅមូលដ្ឋាន

- អភិវឌ្ឍសហគ្រិនភាពខ្នាតតូច និងមធ្យម
- ស្វែងរកវិនិយោគិន ផលិត កែច្នៃដំណាំកសិផល។

## ៦. គោលនយោបាយទេសចរណ៍

- បង្កើតតំបន់ទេសចរណ៍សហគមន៍ (ធម្មជាតិ និងវប្បធម៌)
- រៀបចំទីមហោស្រព ទីលានកីឡា សួនកំសាន្ត និងចំណតផ្សារ។

## ៧. គោលនយោបាយសុខាភិបាល និងសង្គមកិច្ច

- ព្យាបាលជម្ងឺដោយមិនបង់ប្រាក់នៅតាមមណ្ឌលសុខភាព
- បរិស្ថានស្អាត រស់នៅស្អាត
- មិនទុកឲ្យកុមារ ស្ត្រីមេម៉ាយ ចាស់ជរា ជនពិការ ជនខ្វះទីពឹង ជនរងគ្រោះខ្វះការយកចិត្តទុកដាក់ឡើយ។

**គណបក្ស ឆន្ទៈខ្មែរ**
**គ.ឆ.ខ**

**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា សូមគោរពបងប្អូនប្រជាពលរដ្ឋកម្ពុជា ជាទីគោរពរាប់អាន និងជាទីស្រឡាញ់!**

ជាបឋម ខ្ញុំសូមសម្តែងនូវការគោរព និងសេចក្តីស្រឡាញ់ ដ៏ជ្រាលជ្រៅបំផុតចំពោះបងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ជ្រាបថា **គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** មានគោលនយោបាយ៦ចំណុចដូចខាងក្រោមនេះ៖ គឺដើម្បីឱ្យបងប្អូនជាម្ចាស់អំណាចពិតប្រាកដ បញ្ឈប់អំពើអយុត្តិធម៌ក្នុងសង្គម បញ្ឈប់ការរើសអើងជាតិសាសន៍ គោរពសិទ្ធិមនុស្ស បញ្ឈប់ការរំលោភដីធ្លីរបស់បងប្អូនប្រជាពលរដ្ឋពីបុគ្គលអ្នកមានលុយ និងអំណាចមួយចំនួន បញ្ឈប់អំពើការគាបសង្កត់គំរាមកំហែង បញ្ឈប់ការប្រព្រឹត្តអំពើពុករលួយ និងឱ្យបងប្អូនប្រជាពលរដ្ឋមានភាពជាម្ចាស់លើដីធ្លីរបស់ខ្លួន។

#១ .**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** ថែរក្សាអត្តសញ្ញាណជនជាតិដើមមិនឱ្យបាត់បង់។

#២ .**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** ផ្តល់សេវាសាធារណៈ ឱ្យទាន់ពេលវេលា និងមិនគិតកម្រៃពីប្រជាពលរដ្ឋឡើយ។

#៣ .**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** អភិវឌ្ឍ ឃុំសង្កាត់ ដែលនៅជាប់ព្រំដែន និងត្រូវសហប្រតិបត្តិការល្អជាមួយនឹងប្រទេសជិតខាង។

#៤ .**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** ការពារធនធានធម្មជាតិ មិនអនុញ្ញាតឱ្យបំផ្លាញបន្តពីជនខិលខូចព្រមទាំងអនុវត្តច្បាប់ឱ្យស្មើភាពគ្នា។

#៥ .**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** បញ្ឈប់ ការរើសអើងអ្នកនយោបាយគ្រប់រូបភាព។

#៦. **គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន អំពើហិង្សា និងការពារសុវត្ថិភាពប្រជាពលរដ្ឋ។

បងប្អូនប្រជាពលរដ្ឋកម្ពុជា ជាទីគោរពស្រឡាញ់! ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០២២ ខាងមុខនេះត្រូវនឹងថ្ងៃអាទិត្យ គឺថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលជាការបោះឆ្នោតដ៏សំខាន់បំផុតក្នុងការកែប្រែដំណើរការអភិវឌ្ឍឃុំ សង្កាត់នីមួយៗ និងជាថ្ងៃដែលយើងមានសិទ្ធិអំណាចពេញទី ក្នុងការធ្វើជាម្ចាស់ដើម្បីសម្រេចនូវជោគវាសនានិងការអភិវឌ្ឍដែលយើងចង់បាន។ អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ជឿជាក់លើគោលនយោបាយរបស់ **គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** សូមអញ្ជើញទៅបោះឆ្នោតគាំទ្រ **គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** ដែលមាន **"ពណ៌បៃតង ជុំវិញរាងព្រះច័ន្ទពេញបូរមី មានមនុស្សជិះដំរីនៅកណ្តាល"** ជាសញ្ញាសម្គាល់ ឱ្យបានគ្រប់គ្នាកុំបីខាន នៅតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗរបស់ខ្លួន។

**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** សូមប្តេជ្ញានៅចំពោះមុខបងប្អូនប្រជាពលរដ្ឋកម្ពុជា ថានិងធ្វើការកែប្រែការអភិវឌ្ឍនៅមូលដ្ឋាន ឱ្យមានតម្លាភាព យុត្តិធម៌ សមធម៌ និងប្រកបដោយនិរន្តរភាព ព្រមទាំងយកបងប្អូនប្រជាពលរដ្ឋជាម្ចាស់អំណាចពិតប្រាកដ។

**សូមជូនពរឱ្យប្រជាពលរដ្ឋកម្ពុជា បានជួបប្រទះសុខភាពល្អ រីកចម្រើន និងសុភមង្គលជារៀងរហូត។**

មណ្ឌលគិរី, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២

**ប្រធានគណបក្ស**

**ឆ្លាច ស៊ីន**

# គណបក្សឯកភាពជាតិខ្មែរ

**EKPHEAP CHEATKHMER PARTY**

រួបរួម កសាង ការពារ

គណបក្សឯកភាពជាតិខ្មែរ (គ.ឯ.ជ) បានដាក់ចុះនូវគោលនយោបាយ អាទិភាព ៩ ចំណុច សម្រាប់អនុវត្តនៅក្នុងឃុំ សង្កាត់ គឺ៖

១. បម្រើសេវារដ្ឋបាលសាធារណៈជូនពលរដ្ឋបានឆាប់រហ័ស តម្លាភាព គ្មានការរើសអើង និងគ្មានអំពើពុករលួយ
២. បង្កើតក្រុមអាជ្ញាកណ្តាល ដើម្បីដោះស្រាយទំនាស់នានាក្រៅប្រព័ន្ធតុលាការជូនពលរដ្ឋដោយប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ សុចរិតភាព និងមិនប្រកាន់និន្នាការនយោបាយ
៣. ទប់ស្កាត់នូវរាល់ការដាំដុះ ការផលិត ការជួញដូរ ការចែកចាយ និងការប្រើប្រាស់សារធាតុញៀនផ្សេងៗ
៤. ទំនាក់ទំនង សហការជាមួយអ្នកវិនិយោគ អង្គការសង្គមស៊ីវិល ដើម្បីបង្កើតវិស័យការងារ និងដោះស្រាយវិបត្តិសេដ្ឋកិច្ចជូនពលរដ្ឋ
៥. ពង្រឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋានប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់
៦. បង្កើតនូវសេវាសង្គ្រោះបន្ទាន់នៅតាមមណ្ឌលសុខភាព និងបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការបម្រើសេវាសុខភាពជូនពលរដ្ឋប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ល្អ
៧. បង្កើត ជំរុញលើកទឹកចិត្ត គាំទ្រនូវកម្មវិធីបណ្តុះបណ្តាលវិស័យនានា និងការអប់រំផ្នែកគុណធម៌ សីលធម៌ និងសុជីវធម៌
៨. លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពរបស់ពលរដ្ឋគ្រប់រូប និងការគោរពសិទ្ធិមនុស្ស
៩. សាទរ ទទួលយកនូវមតិរិះគន់ពីគ្រប់មជ្ឈដ្ឋាន ដែលមានប្រយោជន៍ដល់ការអភិវឌ្ឍ និងសុខសន្តិភាពជូនជាតិមាតុភូមិ

**បោះឆ្នោតជូនគណបក្សឯកភាពជាតិខ្មែរ ដើម្បីសេចក្តីសុខសាន្ត និងការអភិវឌ្ឍ !**

**គណបក្សឯកភាពជាតិខ្មែរ** ✓



**គុជ លី**
ប្រធានគណបក្ស
ជាទីប្រឹក្សាប្រជាពលរដ្ឋនៅឃុំ-សង្កាត់

# គណបក្សខ្មែរតែមួយ មានគោលនយោបាយឃុំសង្កាត់ ជាអាទិភាព "៧ ចំណុច" ក្នុងការចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

**១-សេវាសាធារណ:** ៖ មេឃុំ ចៅសង្កាត់ ត្រូវគោរពពេលវេលាម៉ោងធ្វើការជាដាច់ខាត។ ការពង្រឹង "**អភិបាលកិច្ចល្អ**" ដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព សុចរិតភាព និងភាតរភាពរវាងខ្មែរនិងខ្មែរ។

**២-ការគ្រប់គ្រងដីធ្លី** ៖ មេឃុំ ចៅសង្កាត់ ត្រូវអនុវត្តតួនាទីក្នុងមុខតំណែងដោយឯករាជ្យភាពដើម្បីគ្រប់គ្រងដីធ្លីឱ្យមានតម្លាភាព និងការលុបបំបាត់ចោលនូវ "**វប្បធម៌អន្តរាគមន៍**" ពីមន្ត្រីថ្នាក់ជាតិ មកកាន់មន្ត្រីថ្នាក់ក្រោមជាតិ ដែលជាហេតុនាំឱ្យមានអំពើពុករលួយជាប្រព័ន្ធ។

**៣- កសិកម្ម** ៖ ការបង្កើត "**សភាកសិករ**" នៅឃុំសង្កាត់ ដើម្បីជួយការពារតម្លៃស្រូវ ការកំណត់តម្លៃស្រូវ អង្ករ និងផលិតផលកសិកម្មផ្សេងៗទៀត កុំឱ្យឈ្មួញកណ្តាលបង្អាប់តម្លៃតាមតែអំពើចិត្ត។

**៤-មណ្ឌលសុខភាព** ៖ ការពង្រឹង និងពង្រីកបន្ថែមមណ្ឌលសុខភាពមូលដ្ឋាន ដើម្បីផ្តល់សេវាឱ្យរហ័សទាន់ចិត្តជូនប្រជាពលរដ្ឋដោយគ្មានការរើសអើង និង"**ទិញរថយន្តសង្គ្រោះបន្ទាន់មួយគ្រឿងក្នុងមួយឃុំសង្កាត់**" ដើម្បីជួយសង្គ្រោះបឋមដល់អាយុជីវិតប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

**៥-មនុស្សចាស់គ្មានទីពឹង** ៖ ចាប់ពីអាយុ៦០ឆ្នាំឡើងទៅ មានការធានាថែទាំពីរដ្ឋបាលឃុំសង្កាត់ដោយមានប្រាក់ឧបត្ថម្ភក្នុងមួយនាក់ "**១៥ ម៉ឺនរៀល**" ជារៀងរាល់ខែ។

**៦-សន្តិសុខ** ៖ នគរបាលការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ និងការបង្ក្រាបទប់ស្កាត់នូវសកម្មភាព បងធំបងតូច ចោរលួចចោរប្លន់ ការផលិតនិងសេពគ្រឿងញៀន និងអំពើហិង្សានានា នៅក្នុងភូមិឃុំសង្កាត់។

**៧-យុវជនខ្មែរជំនាន់ថ្មី៖** មេភូមិ មេឃុំ ចៅសង្កាត់ ចូលរួមធ្វើចលនា "**បណ្តុះគំនិត គិតសង្គមជាតិ**" ដើម្បីយុវជនខ្មែរជំនាន់ក្រោយៗដោយគ្មានវប្បធម៌លាបពណ៌ និងគ្មានវប្បធម៌ក្តិចត្រួយ ។

**គណបក្សខ្មែរតែមួយ**
**គ.ខ.ម**

## គណបក្សយុវជនកម្ពុជា
CAMBODIAN YOUTH PARTY ✓

# គោលនយោបាយ ឃុំ សង្កាត់ ៧ ចំណុច
## អាណត្តិទី៥ ឆ្នាំ២០២២

១.បើកវេទិកាសាធារណៈមួយខែម្តង ជួបជាមួយប្រជាពលរដ្ឋ ដើម្បីដោះស្រាយនូវបញ្ហានានានៅក្នុងមូលដ្ឋាន ឃុំ សង្កាត់

២.បោសសម្អាតការលក់និងប្រើប្រាស់គ្រឿងញៀនក្នុងមូលដ្ឋាន

៣.ទិញរថយន្តសង្គ្រោះបន្ទាន់ដឹកពលរដ្ឋមានជម្ងឺក្នុងមូលដ្ឋាន ឃុំ សង្កាត់បញ្ជូនទៅមន្ទីរពេទ្យដោយមិនគិតថ្លៃសេវាដឹកទេ

៤.ចាស់គ្មានទីពឹងចាប់ពីអាយុ៦០ឆ្នាំឡើងទៅទទួលបានប្រាក់ឧបត្ថម្ភ១០ម៉ឺនរៀលក្នុងម្នាក់រៀងរាល់ខែ និងទទួលបានការថែទាំយ៉ាងយកចិត្តទុកដាក់ពីរដ្ឋបាលឃុំ សង្កាត់របស់យើង

៥.ពង្រឹងការផលិតកសិកម្ម ដើម្បីទទួលបានទីផ្សារលក់បានថ្លៃ

៦.បើកវគ្គបណ្តុះបណ្តាលពហុជំនាញដល់យុវជនក្នុងមូលដ្ឋាន ឃុំ សង្កាត់ ឱ្យមានជំនាញច្បាស់លាស់ និងមានរបរត្រឹមត្រូវ

៧.ពង្រឹងការប្រើប្រាស់ថវិកា ឃុំ  សង្កាត់ ឱ្យមានតម្លាភាព និងបង្កើនថវិកា ឃុំ សង្កាត់ ៦០ម៉ឺនដុល្លារក្នុង១ឆ្នាំ ដើម្បីពន្លឿនការអភិវឌ្ឍនានា ដែលចាំបាច់នៅក្នុងមូលដ្ឋានឃុំ សង្កាត់។

គណបក្សប្រជាធិបតេយ្យមូលដ្ឋាន
Grassroots Democratic Party
សាមគ្គីភាព យុត្តិធម៌ អហិង្សា

# គោលនយោបាយ ស៥ ដើម្បីកសាងឃុំ សង្កាត់គំរូ សម្រាប់គាំទ្រឱ្យ *ប្រជាពលរដ្ឋរស់នៅមានជីវិតថ្លៃថ្នូរ*

## ស១ សេដ្ឋកិច្ច

- កសិករមានសមត្ថភាពដោះស្រាយបញ្ហាទឹក ទុន ទីផ្សារ និងបំណុល
- គ្រប់ភូមិមានផ្លូវល្អ មានភ្លើងអគ្គិសនីប្រើប្រាស់
- បង្កលក្ខណៈងាយស្រួលដល់សិប្បករ អាជីវករ និងសហគ្រិនក្នុងការប្រកបមុខរបរ
- រៀបចំឱ្យមានតំបន់ទេសចរណ៍កសិកម្ម ធម្មជាតិ និងវប្បធម៌

## ស២ សុខាភិបាល

- គ្រប់ឃុំសង្កាត់ មានមណ្ឌលសុខភាពល្អ មានបរិក្ខារគ្រប់គ្រាន់ និងថ្នាំព្យាបាលត្រឹមត្រូវ
- តាមភូមិមានគ្រូពេទ្យល្អ ផ្តល់ប្រឹក្សាអំពីសុខភាព
- ភូមិឃុំ សង្កាត់ មានអនាម័យ និងទឹកស្អាត និងបរិស្ថានល្អ។

## ស៣ សិក្សាធិការ និងយុវជន

- តាមភូមិឃុំ សង្កាត់ មានសាលាស្អាត គ្រូបង្រៀនល្អ និងមានបណ្ណាល័យត្រឹមត្រូវ
- គ្រប់ភូមិមានសាលាមត្តេយ្យប្រកបដោយគុណភាព
- យុវជន យុវនារី មានវិជ្ជាជីវៈច្បាស់លាស់អាចប្រកបមុខរបរបាន។

## ស៤ សង្គមកិច្ច

- ចាស់ជរាគ្រប់រូប ទទួលបានការឧបត្ថម្ភ
- ក្មេងកំព្រា ជនពិការ គ្រួសារក្រីក្រ និងជួបការលំបាកខ្លាំងដោយសារកូវីដ-១៩ទទួលបានការឧបត្ថម្ភ

## ស៥ សេវា និងសម្បត្តិសាធារណៈ

- សេវារដ្ឋបាលទាន់ចិត្ត មិនរើសអើងនយោបាយ និងមិនពុករលួយ
- ប្រជាជនរស់នៅមានសុវត្ថិភាព និងមានសេរីភាពនយោបាយ
- តាមភូមិ ឃុំ សម្បូរទឹក ព្រៃ និងត្រី ឡើងវិញ
- រៀបចំឱ្យមានគណៈកម្មាធិការឃ្លាំមើលនិងតម្រង់ទិសការដឹកនាំឃុំ សង្កាត់
- ការពារកុំឲ្យមាននិងលុបបំបាត់ការប្រើប្រាស់គ្រឿងញៀន។

# គណបក្សកែទម្រង់កម្ពុជា

## កែប្រែរបៀបដឹកនាំប្រទេស ដើម្បីអនាគតជាតិខ្មែរ

គណបក្សកែទម្រង់កម្ពុជា យល់ឃើញថា ដើម្បីគ្រប់គ្រងឃុំ សង្កាត់ឲ្យមានប្រសិទ្ធភាព និងអភិវឌ្ឍប្រកបដោយសមធម៌ ការធ្វើកំណែទម្រង់ថវិកាថ្នាក់ក្រោមជាតិ(ឃុំ សង្កាត់) និងកំណែទម្រង់ដោយការធ្វើវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ ត្រូវធ្វើជាចាំបាច់៖

* កំណែទម្រង់ថវិកាថ្នាក់ក្រោមជាតិ(ឃុំ សង្កាត់)៖ បង្កើនកញ្ចប់ថវិកា ឃុំ សង្កាត់ឲ្យបាន ពី២៥ម៉ឺន ទៅ ៤៥ម៉ឺនដុល្លារក្នុងមួយឆ្នាំ សម្រាប់ឃុំ សង្កាត់នីមួយៗ យកទៅអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយបញ្ហាអសកម្មផ្សេងៗ និងដំឡើងប្រាក់បំណាច់មធ្យមប្រចាំខែ របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ៗ ឲ្យដល់៥៥០ដុល្លារ។
* កំណែទម្រង់ច្បាប់គ្រប់គ្រងឃុំ សង្កាត់៖ បែងចែកឲ្យបានច្បាស់ រវាងតួនាទីជាអ្នកបម្រើប្រជាពលរដ្ឋ និងតួនាទីជាមន្ត្រីរបស់គណបក្សនយោបាយ។ ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ធ្វើញត្តិដកសេចក្តីទុកចិត្ត ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬ មេភូមិ ដែលពលរដ្ឋបានជ្រើសរើស។

កំណែទម្រង់ទាំងពីរខាងលើនេះ មានគោលដៅគាំទ្រការអនុវត្ត គោលនយោបាយឃុំ សង្កាត់ ឆ្នាំ២០២២ ដូចខាងក្រោម៖

១- លើកកម្ពស់និងពង្រឹងសិទ្ធិអំណាចប្រជាពលរដ្ឋនៅមូលដ្ឋាន

* ផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋ ចូលរួមផ្តល់យោបល់លើការសម្រេចចិត្តក្នុងការអនុវត្ត និងសម្តែងកង្វល់តាមរយៈវេទិកាសាធារណៈនៅតាមមូលដ្ឋាន។
* លើកទឹកចិត្តប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពនយោបាយ ដោយគ្មានការបំភិតបំភ័យនិងរារាំង។

២- បំបាត់ការរើសអើងនយោបាយ

* បម្រើប្រជាពលរដ្ឋដោយមិនប្រកាន់ និន្នាការនយោបាយ សាសនា ពូជអម្បូរ ឬ ឋានៈ។
* ផ្តល់ភាពស្មើគ្នាក្នុងការទទួលបានសេវាកម្ម ការបែងចែកផ្នែកសង្គមកិច្ច និងអត្ថប្រយោជន៍នៃការអភិវឌ្ឍដល់ប្រជាពលរដ្ឋ។

៣- រក្សាភាពស្អាតស្អំនិងតម្លាភាពនៅក្នុងមូលដ្ឋាន

* បំបាត់អំពើពុករលួយគ្រប់ប្រភេទក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។
* បំពេញតួនាទីតាមច្បាប់កំណត់ឲ្យបានទាន់ពេលវេលា និងយកតម្លៃសេវាកម្មតាមច្បាប់កំណត់។

៤- លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ការពារផលប្រយោជន៍សហគមន៍ និងទ្រព្យសម្បត្តិឯកជន។

* លើកកម្ពស់ជីវភាពប្រជាពលរដ្ឋតាមរយៈការបង្កើតគម្រោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់។
* បំបាត់ការបំពារបំពាន និងការកេងប្រវ័ញ្ចយកដីធ្លីពីប្រជាពលរដ្ឋ។
* ទប់ស្កាត់ការបំផ្លិចបំផ្លាញធនធានធម្មជាតិ រ៉ែ ព្រៃឈើ ព្រៃលិចទឹក ព្រៃកោងកាង មច្ឆាជាតិ...។ល។

៥- ពង្រឹង ការពារសន្តិសុខនិងសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន

* ទប់ស្កាត់គ្រឿងញៀន ចោរកម្ម និងក្រុមក្មេងទំនើង។
* បំបាត់អំពើហិង្សាក្នុងគ្រួសារ និងក្នុងសង្គម។

**បោះឆ្នោតឲ្យគណបក្សកែទម្រង់កម្ពុជា គ្រប់គ្នាមានមេឃុំសុចរិត**

## គោលនយោបាយគណបក្ស "កម្ពុជានិយម"




**កម្ពុជានិយម** គោលនយោបាយអាទិភាពឃុំ-សង្កាត់

«សាលាគំរូ ពេទ្យល្អ ភូមិឃុំបវរ ជីវភាពរុងរឿង»

**១. សេវារដ្ឋបាលសាធារណៈ៖** បម្រើរាស្ត្ររហ័សទាន់ពេល មិនពុករលួយ មិនរើសអើង ក្រមសីលធម៌ល្អ

**២. សេវាសន្តិសុខ៖** ដោះស្រាយបញ្ហាគ្រឿងញៀន ចោរកម្ម ល្បែងស៊ីសង។ «វេទិកាសន្តិសុខភូមិយើង» «មូលនិធិនគរបាលល្អ»

**៣. សេវាសេដ្ឋកិច្ច(កសិកម្ម សិប្បកម្ម...)៖** ដោះស្រាយ ទុន ទីក ទីផ្សារ ទំនាក់ទំនង បច្ចេកទេស។ «វេទិកាទីផ្សារ» «ក្រុមបច្ចេកទេសកសិកម្ម» «សហគមន៍សន្សំប្រាក់» «អាងទឹក ស្រះ ប្រឡាយ»

**៤. សេវាសុខាភិបាល៖** មណ្ឌលសុខភាពបម្រើរាស្ត្រ ស្ត្រី កុមារ ចាស់ជរា(រកសម្ភារៈពេទ្យ ថ្នាំសង្កូវជាមូលដ្ឋាន ការដឹកអ្នកជំងឺខ្វះខាត)។ «វេទិកាគ្រូពេទ្យល្អ» «គាំពារសុខភាពស្ត្រីមានផ្ទៃពោះ-កុមារ»

**៥. សេវាអប់រំ៖** សាលារៀនមានបរិស្ថានស្អាត អនាម័យល្អ កន្លែងកីឡា បណ្ណាល័យ និងសម្ភារៈ ផ្សេងទៀត។ «វេទិកាគ្រូបង្រៀនល្អ ក្រមសីលធម៌ខ្ពស់» «មូលនិធិសាលារៀនគំរូ»។

**៦. សេវាគុណភាពជីវិត៖** សិទ្ធិសេរីភាព សុវត្ថិភាពស្បៀង និងចំណីអាហារ បរិស្ថាន អនាម័យ យុត្តិធម៌សង្គម សន្តិសុខ-សុវត្ថិភាព។ «វេទិកាគុណភាពជីវិតអ្នកភូមិ ឃុំ-សង្កាត់បៃតង ទំនើបជឿនលឿន»

*"សន្លឹកឆ្នោតខ្ញុំ សន្លឹកឆ្នោតអ្នក អនាគតឃុំ-សង្កាត់យើង!"*

**"កម្ពុជា"** ជាទឹកដីកំណើតរបស់យើង! យើងជាសមាជិកនៃសង្គមត្រូវចូលរួមរៀបចំកសាងអនាគតថ្មីដើម្បីកម្ពុជា! ថែរក្សាការពារអត្តសញ្ញាណជាតិ រៀបចំសង្គមស៊ីវិល័យ ជឿនលឿនថ្លៃថ្នូរ ប្រជាធិបតេយ្យសេរី សិទ្ធិសេរីភាព យុត្តិធម៌សង្គម គឺជាបំណងប្រាថ្នាដែលយើងចង់បាន នូវសង្គមមួយរួមរស់ដោយសុខដុមរមនាទាំងអស់គ្នា ក្នុងនាមយើងជាខ្មែរម្ចាស់វាសនា **"កម្ពុជា"**។

ប្រទេសយើង មានយុវជន មានថាមពល មានសក្តានុពល មានបំណងចង់ផ្លាស់ប្តូរជាវិជ្ជមាន ប៉ុន្តែវានៅមានភាពមិនទទួលយកនូវទស្សនៈផ្សេងគ្នា នៅក្នុងសង្គមប្រជាធិបតេយ្យសេរីរបស់យើង។ យើងធ្វើការកែទម្រង់ យើងមានថាមពល យើងមានមហិច្ឆតានៅក្នុងការកសាងសង្គមកម្ពុជា ដែលយើងជឿជាក់យ៉ាងខ្លាំងលើប្រជាពលរដ្ឋយើង យុវជនយើង ថាយើងអាចធ្វើបានដើម្បីកម្ពុជា!។

*"ឥន្រ្ទីកម្ពុជានិយម សកម្មបម្រើរាស្ត្រ!"*

គណបក្សកម្ពុជានិយម ផ្តល់គុណតម្លៃនៃការរស់នៅដោយសមរម្យ ថ្លៃថ្នូររបស់មនុស្ស រួមមាន៖ ដីធ្លីផ្ទះសម្បែង សម្លៀកបំពាក់ ចំណីអាហារ ថ្នាំសង្កូវ ការសិក្សារៀនសូត្រ ការងារសមរម្យ។ ដូច្នេះសេដ្ឋកិច្ចគ្រួសារ ការងារ សុខភាព អប់រំ សេរីភាព យុត្តិធម៌របស់យើងទាំងអស់គ្នាតាមមូលដ្ឋានឃុំ-សង្កាត់។ គំនិតទស្សនៈថ្មីៗ យើងដើរទៅមុខ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ ជំរុញលើកទឹកចិត្តស្ត្រី និងយុវជន ក្នុងការចូលរួមដោះស្រាយរៀងរាល់បញ្ហាដែលវាជារឿងរបស់យើងទាំងអស់គ្នា។ ស្ត្រី និងយុវជនបន្តវេនមានសុច្ឆន្ទៈពិតប្រាកដ ដែលចង់ធ្វើអ្វីមួយដ៏ល្អសម្រាប់សង្គមមានសេវាសាធារណៈរហ័ស ស្អាតស្អំ មិនរើសអើង បរិស្ថានល្អ ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន នៅពេលដែលក្លាយជាមន្ត្រីជាប់ឆ្នោត។ *«មេឃុំ-ចៅសង្កាត់ស្អាតស្អំ សកម្មបម្រើរាស្ត្រ!»*

យើងផ្តល់សេរីភាពត្រឡប់មកវិញ យើងផ្តល់សិទ្ធិស្មើគ្នា យុត្តិធម៌កាន់តែច្រើន ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍ។ ដូច្នេះ យើងជឿជាក់លើសេរីភាពសេដ្ឋកិច្ច សេរីភាពសង្គម និងសេរីភាពនយោបាយ ដោយគ្មានភាពផ្តាច់មុខ **"កសាងអនាគតថ្មីដើម្បីកម្ពុជា!"**។ *«មេឃុំ-ចៅសង្កាត់ល្អ ភូមិឃុំសុវត្ថិភាព!»*

**"កសាងអនាគតថ្មីដើម្បីកម្ពុជា!"** ពិតហើយ ដល់ពេលហើយ បោះឆ្នោតគាំទ្រគណបក្សកម្ពុជានិយម ដែលគោលដៅរបស់យើង គឺដោះស្រាយនៅអ្វីដែលជាភាពអសកម្ម អវិជ្ជមាន ដូចជាអំពើពុករលួយ អយុត្តិធម៌សង្គម បរិស្ថាន ការរើសអើង ការងារ សេដ្ឋកិច្ចគ្រួសារ... ដែលនៅមានតាមឃុំ-សង្កាត់។ ចាប់ផ្តើមពីឥឡូវនេះ នោះគឺជាអ្វីដែលអ្នកនឹងធ្វើជាមួយ **"កម្ពុជានិយម"**។ **"កម្ពុជានិយម"** គឺបង្កើតឡើងក្នុងគោលបំណងដោះស្រាយបញ្ហា រៀបចំកសាងឃុំ-សង្កាត់ និងការដឹកនាំឃុំ-សង្កាត់ ដឹកនាំប្រទេសតាមឆន្ទៈរបស់ប្រជាពលរដ្ឋ។

*«មេឃុំ-ចៅសង្កាត់អភិវឌ្ឍ ភូមិឃុំរុងរឿង»*




**យើងបោះឆ្នោតគាំទ្រគណបក្សកម្ពុជានិយម ដែលមានរូបឥន្រ្ទី!**

# គោលនយោបាយរបស់គណបក្ស សញ្ជាតិកម្ពុជា



**គណបក្សសញ្ជាតិកម្ពុជាមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នា មានគោលនយោបាយជាសច្ចភាព៤ខ គឺសាមគ្គីធម៌ប្រជាជាតិ ធ្វើបុណ្យរក្សាសីលនិងបណ្តុះគ្រាប់ពូជព្រះនិព្វានបានដាក់ចេញនូវគោលការណ៍ក្នុងការដោះស្រាយបាតុភាពផ្សេងៗ នៅក្នុងឃុំសង្កាត់យើងខ្ញុំដូចតទៅ៖**

-គណបក្សសញ្ជាតិកម្ពុជា មានបាវចនា សញ្ជាតិ សាសនា អធិបតេយ្យ មានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នា

-ព្រះអាទិត្យនិងព្រះចន្ទជួបគ្នាតំណាងឱ្យ ការរួបរួមគ្រប់ស្រទាប់ប្រជារាស្ត្ររស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់រើសអើងនិន្នាការនយោបាយ ជំនឿ សាសនា និងជាតិសាសន៍ឱ្យតែអ្នកទាំងនោះត្រូវបានទទួល ស្គាល់ដោយច្បាប់សញ្ជាតិនិងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះអាទិត្យពណ៌មាសនិងព្រះចន្ទពណ៌ប្រាក់តំណាងឱ្យលទ្ធិប្រជាធិបតេយ្យ សន្តិភាពនិងសហប្រតិបត្តិការរបស់សញ្ជាតិខ្មែរគ្រប់រូបដើម្បីការអភិវឌ្ឍនិងភាពចុំច្រើងរុងរឿង។

-គណបក្សសញ្ជាតិកម្ពុជាជាស្នាព្រះហស្តដ៏ថ្លៃថ្លារបស់លោកឪ លោកតាមហាឪ ព្រះរស់ព្រហ្មបួនអសង្ខេយ្យ។ ព្រះអង្គជាព្រះប្រធានចលនាតស៊ូផ្ទៃក្នុងប្រឆាំងនឹងបរទេសឈ្លានពានតាំងពីទសវត្សរ៍ឆ្នាំ ១៩៨០ និងជាព្រះប្រធានស្ថាបនិក នៃគណបក្សសញ្ជាតិកម្ពុជាព្រះអង្គតែងតែរួមសុខរួមទុក្ខជាមួយប្រជារាស្ត្ររបស់ព្រះអង្គគ្រប់កាលៈទេសៈ។

| | |
|---|---|
| √ | **គណបក្សសញ្ជាតិកម្ពុជា** |

# គណបក្សហ្វ៊ុនស៊ិនប៉ិច ជ្រើសតាំងព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ដឹកនាំបន្តវេនពី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ



ព្រះអង្គម្ចាស់នរោត្តម ចក្រាវុធ ព្រះបុត្រាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងជាព្រះប្រធានគណបក្សហ៊្វុនស៊ីនប៉ិច ឆ្នាំ២០២២



សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ឆ្នាំ១៩៩៣






ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ព្រះបុត្រាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានសមាជវិសាមញ្ញគណបក្ស ហ៊្វុនស៊ិនប៉ិច ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ ជ្រើសតាំងជាព្រះប្រធាន ដឹកនាំបន្តវេន ពី សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ។

ព្រះអង្គជាព្រះញាតិវង្សានុវង្សមួយអង្គដ៏មានប្រជាប្រិយភាព មានការសិក្សាខ្ពស់ ធ្លាប់បានដង្ហែព្រះបិតាចូលរួមកិច្ចការនយោបាយគណបក្សនិង សង្គមជាតិជាច្រើនឆ្នាំ។

# ទិសដៅធំៗនៃគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ ២០២២-២០២៧

**គណបក្សប្រជាជនកម្ពុជា** ធានាបន្តការអភិវឌ្ឍឃុំ សង្កាត់ ឱ្យបាន សម្រេចជោគជ័យតាមទិសដៅដូចខាងក្រោម ៖

១- ជាឃុំសង្កាត់ដែលជានាការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាព របស់ប្រជាជនតាមគន្លងនីតិរដ្ឋ ដើម្បីលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងធ្វើឱ្យប្រជាជនបានរស់នៅដោយ សុខដុមរមនាក្រោមម្លប់នៃសន្តិភាព

២- ជាឃុំ សង្កាត់ដែលមានសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមកាន់តែល្អប្រសើរ

៣- ជាឃុំ សង្កាត់ដែលធានាការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព តម្លាភាព និងជឿទុកចិត្ត

- ប្រជាពលរដ្ឋទទួលបានសេវារដ្ឋបាលប្រកបដោយភាពងាយស្រួល សាមញ្ញ និងឆាប់រហ័ស តាមរយៈការរៀបចំយន្តការ ច្រកចេញចូលតែមួយ។ ការចុះបញ្ជីកំណើត បញ្ជីអាពាហ៍ពិពាហ៍ បញ្ជីមរណភាព ការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ
- កុមារ និងយុវជនបានរៀនសូត្រគ្រប់គ្នាប្រកបដោយសមធម៌ និងគុណភាព ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរដ្ឋ ការបង្កឱកាសគ្រប់យ៉ាងឱ្យកុមារ និងយុវជនបានចូលរៀន និងការបង្កើតសាលារៀនឱ្យទៅជិតលំនៅឋានប្រជាជន
- ប្រជាជនទូទៅទទួលបានសេវាសុខភាពកាន់តែប្រសើរឡើងនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ ហើយចូលរួម យ៉ាងសកម្មក្នុងការលើកកម្ពស់របៀបរស់នៅតាមគន្លងថ្មី។ ប្រជាជនក្រីក្រ និងអ្នកខ្វះលទ្ធភាពទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតបង់ថ្លៃនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ
- គ្រប់ឃុំ សង្កាត់មានផ្លូវគមនាគមន៍កាន់តែច្រើន និងកាន់តែល្អ, មានអគ្គិសនី និងទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់, មានប្រព័ន្ធទឹកស្រោចស្រពដំណាំកាន់តែប្រសើរឡើង, មានសេវាទូរគមនាគមន៍ប្រកបដោយគុណភាព, មាន បរិស្ថានបៃតង អនាម័យស្អាត, មានការការពារ ការអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព
- បន្តមិនយកពន្ធដីកសិកម្មរបស់កសិករដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ បែងចែកដី និងផ្តល់កម្មសិទ្ធិដីជូនគ្រួសារ ក្រីក្រគ្មានដីសម្រាប់ស្នាក់នៅ និងបង្កបង្កើនផលចិញ្ចឹមជីវិត ដែលបានអនុវត្តស្របតាមលក្ខខណ្ឌសម្បទានដីសង្គមកិច្ច

៤- ជាឃុំ សង្កាត់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីលើកស្ទួយជីវភាពប្រជាជន តាមរយៈការបង្កើនការងារ, ការពង្រីក មុខរបរ ការអភិវឌ្ឍវិស័យកសិកម្ម និងផលិតកម្មផ្សេងៗទៀត, ការពង្រីកទីផ្សារសម្រាប់ផលិតផលកសិកម្ម និង សិប្បកម្ម, ការផ្តល់ប្រាក់កម្ចីមានអត្រាការប្រាក់ទាបសមរម្យសម្រាប់បង្កើត និងពង្រីកមុខរបរ, ការរក្សាស្ថិរភាពថ្លៃ ស្បៀងអាហារ និងថ្លៃទំនិញចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ, ការធ្វើអន្តរាគមន៍ពីរដ្ឋលើថ្លៃលក់កសិផលរបស់ប្រជា-ពលរដ្ឋដោយរក្សាបានសេដ្ឋកិច្ចទីផ្សារ និងសន្តិសុខសង្គម។ អាជីវករលក់ដូរតាមផ្សាររដ្ឋ និងទីតាំងផ្សាររដ្ឋ មានសិទ្ធិ កាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើតូប រាន ស្តង់លក់ដូរ និងមានសិទ្ធិផ្ទេរសិទ្ធិទាំងនេះជូនកូនចៅ ឬអ្នកដទៃ

៥- ជាឃុំ សង្កាត់ដែលលើកកម្ពស់ការគាំពារសង្គម និងលើកកម្ពស់ស្ថានភាពរស់នៅរបស់ស្ត្រី យុវជន កុមារ ជនមាន ពិការភាព ជនចាស់ជរា ជនជាតិដើមភាគតិច អតីតយុទ្ធជន គ្រួសារក្រីក្រ និងប្រជាជនងាយរងគ្រោះផ្សេងទៀត

៦- ជាឃុំ សង្កាត់ ដែលលើកកម្ពស់គណនេយ្យភាពចំពោះប្រជាពលរដ្ឋ យុត្តិធម៌សង្គម និងភាពស្អាតស្អំ គ្មានការ រំលោភអំណាច និងគ្មានអំពើពុករលួយ

៧- ជាឃុំ សង្កាត់ដែលមានស្វ័យភាព សិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីធានាការ អភិវឌ្ឍមូលដ្ឋាន និងការការពារផលប្រយោជន៍របស់ប្រជាជន។

# គណបក្សខ្មែរស្រឡាញ់ជាតិ

## សេរីភាព យុត្តិធម៌ ប្រជាធិបតេយ្យ

*បងប្អូនជនរួមជាតិ បងប្អូនអ្នកស្នេហាជាតិ បងប្អូនអ្នកស្រឡាញ់ប្រជាធិបតេយ្យ សេរីភាព យុត្តិធម៌ ជាទីគោរពស្រឡាញ់!*

ខ្ញុំ **ជីវ កត្តា** ជាអតីតអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងជាប្រធានគណបក្សខ្មែរស្រឡាញ់ជាតិ សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុត។

ដោយមើលឃើញប្រជាពលរដ្ឋ ជាតិ និងមាតុភូមិជាទីស្រឡាញ់របស់យើង នៅតែជួបប្រទះបញ្ហាសង្គម សេដ្ឋកិច្ច និងនយោបាយ។ ប្រព័ន្ធដឹកនាំរដ្ឋតាមគោលការណ៍ប្រជាធិបតេយ្យ សេរីពហុបក្ស និងការគោរពសិទ្ធិមនុស្សមានការធ្លាក់ចុះ។ការអនុវត្តច្បាប់តាមគោល-ការណ៍នីតិរដ្ឋមិនបានពេញលេញ ប្រជាពលរដ្ឋរងគ្រោះ សកម្មជនសង្គម និងអ្នកនយោបាយដែលហ៊ានបញ្ចេញមតិយោបល់ ដើម្បីការពារកម្មសិទ្ធិដីធ្លី ការពារធនធានធម្មជាតិ បរិស្ថាន ដែលជាផលប្រយោជន៍សហគមន៍ និងផលប្រយោជន៍ជាតិត្រូវបានគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោល ចាប់ចង ចាប់ឃុំឃាំងយ៉ាងអយុត្តិធម៌។ការប្រឆាំងអំពើពុករលួយ និងការបម្រើសេវាសាធារណៈគ្មានតម្លាភាព គ្មានប្រសិទ្ធភាពជូនប្រជាពលរដ្ឋ។ ការគ្រប់គ្រង និងការដឹកនាំរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ/សង្កាត់ មិនទាន់មានការអភិវឌ្ឍពិតប្រាកដ មិនមានសមធម៌ និងមិនមានចីរភាព។ ការផ្តល់សិទ្ធិអំណាចជូនប្រជាពលរដ្ឋចូលរួមសម្រេចចិត្តលើការងារកសាង និងអភិវឌ្ឍនានានៅក្នុងឃុំ/សង្កាត់នៅមានកម្រិតនៅឡើយ។ ភាពអសកម្មទប់ស្កាត់ការចរាចរគ្រឿងញៀន ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ក្នុងសហគមន៍ ការគំរាមកំហែងផ្នែកនយោបាយនៅតែបន្តកើតឡើងនៅតាមភូមិ ឃុំ/សង្កាត់នៅឡើយ។

កត្តាទាំងអស់ខាងលើនេះ និងដោយស្មារតីស្រឡាញ់ជាតិ ស្រឡាញ់យុត្តិធម៌ ស្រឡាញ់លទ្ធិប្រជាធិបតេយ្យ យើងខ្ញុំជាអតីតអ្នកតំណាងរាស្ត្រ អ្នកស្នេហាជាតិ អ្នកស្រឡាញ់ប្រជាធិបតេយ្យ អ្នកស្រឡាញ់យុត្តិធម៌ បានសម្រេចបង្កើត**គណបក្សខ្មែរស្រឡាញ់ជាតិ**នេះឡើង ក្នុងគោលបំណងដើម្បីបន្តស្មារតីស្នេហាជាតិនិងចូលរួមដោះស្រាយបញ្ហាជាតិធំៗ ដោះស្រាយបញ្ហាប្រជាពលរដ្ឋខ្មែរដែលកំពុងរងគ្រោះដោយភាពយុត្តិធម៌សង្គម។

នៅថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី៥ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២នេះ ក្នុងនាមប្រធានគណបក្ស សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ បោះឆ្នោតឱ្យ**គណបក្សខ្មែរស្រឡាញ់ជាតិ**ដើម្បីទទួលបានមេឃុំ/ចៅសង្កាត់ស្អាតស្អំ បម្រើរាស្ត្រពិតប្រាកដ ការពារផលប្រយោជន៍រាស្ត្រពិតប្រាកដ និងស្មោះត្រង់ជាមួយរាស្ត្រ៕

### គោលជំហរ ៥ ចំណុចគណបក្សខ្មែរស្រឡាញ់ជាតិ

**១. បន្តស្មារតីស្នេហាជាតិ**
- បន្តជំហរនយោបាយស្នេហាជាតិ
- ការពារផលប្រយោជន៍ជាតិ និងការពារប្រជាពលរដ្ឋរងគ្រោះ
- បន្តគំរូវីរភាពមនសិការជាតិរបស់ឥស្សរជននយោបាយស្នេហាជាតិ
- បន្តបេសកកម្មបម្រើជាតិ។

**២. បង្កើតវប្បធម៌នយោបាយថ្មី**
- មិនសាបព្រោះឱ្យខ្មែរស្អប់ខ្មែរ និងរើសអើងខ្មែរ
- បណ្តុះស្មារតីស្រឡាញ់ជាតិ មិនបណ្តុះស្មារតីស្រឡាញ់បុគ្គល
- បណ្តុះស្មារតីយុវជនឱ្យស្នេហាជាតិ និងចូលរួមនយោបាយ

**៣. ប្រមូលបង្រួមអ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យ**
- ប្រមូលផ្តុំធនធាន គំនិត អ្នកស្នេហាជាតិ អ្នកប្រជាធិបតេយ្យ ដើម្បីឱ្យមានកម្លាំងធំក្នុងការប្រកួតប្រជែងតាមរយៈការបោះឆ្នោតត្រឹមត្រូវ និងយុត្តិធម៌
- ខ្មែរសាមគ្គី ខ្មែរខ្លាំង។

**៤. ផ្សះផ្សាជាតិ (ខ្មែរតែមួយ)**
- ខ្មែររួមគ្នាអភិវឌ្ឍសង្គមជាតិសម្រាប់កូនខ្មែរជំនាន់ក្រោយ
- ខ្មែររួមគ្នាគោរពច្បាប់អនុវត្តច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា (មនុស្សទាំងអស់រស់ក្រោមច្បាប់រដ្ឋធម្មនុញ្ញតែមួយ)
- ខ្មែររួមគ្នាដោះស្រាយបញ្ហាសង្គមជាតិ ការពារសន្តិភាពពិតប្រាកដ ការពារប្រយោជន៍ប្រជាពលរដ្ឋពិតប្រាកដ
- ខ្មែរសាមគ្គី ខ្មែរឈ្នះទាំងអស់គ្នា។

**៥. គស៊ូមតិតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ**
- ធ្វើសកម្មភាពនយោបាយតាមគោលការណ៍ប្រជាធិបតេយ្យ
- គោរពច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- គោរពស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១។

*មេឃុំ/ចៅសង្កាត់គណបក្សខ្មែរស្រឡាញ់ជាតិរូបណាដែលមិនបម្រើរាស្ត្រ នឹងត្រូវដកចេញពីតំណែង!*

**គណបក្សខ្មែរស្រឡាញ់ជាតិ**

**គ.ខ.ស.ជ**

# គណបក្ស ភ្លើងទៀន

## CANDLELIGHT PARTY

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

## បោះឆ្នោតឱ្យគណបក្សភ្លើងទៀន ដើម្បី៖

១- ទទួលបានសិទ្ធិអំណាចចូលរួមផ្តល់យោបល់ ក្នុងការរៀបចំគ្រប់គ្រង និងការសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីមានជីវភាពល្អប្រសើរ

២- ទទួលបានការផ្តល់សេវាសាធារណៈទាំងឡាយ ដោយភាពរួសរាយរាក់ទាក់ ល្អត្រឹមត្រូវ មិនស្មុគស្មាញ ឆាប់រហ័ស និង គ្មានអំពើពុករលួយ

៣- ទទួលបានសន្តិសុខសុវត្ថិភាព ដោយរួមគ្នាធ្វើឱ្យសង្គម គ្មានគ្រឿងញៀន គ្មានអំពើអបាយមុខ និងរស់នៅដោយសុខសាន្តគ្មានការភ័យខ្លាច

៤- ទទួលបានកិច្ចការពារលើកម្មសិទ្ធិដីធ្លី ការលើកតម្កើងជីវភាពដោយមានការងារធ្វើត្រឹមត្រូវ ងាយស្រួលក្នុងការធ្វើអាជីវកម្ម និងមានទីផ្សារលក់ផលិតផល

៥- ទទួលបាននូវកិច្ចប្រឹក្សាយោបល់ ការពារកុំឱ្យមានការជំពាក់បុលមិនចាំបាច់ ការខ្ចីបុលមានការប្រាក់ទាប និងការបង្កើតនូវមូលនិធិសង្គមជួយដល់ជនក្រីក្រ

៦- ការផ្តល់ប័ណ្ណព្យាបាលជម្ងឺដោយឥតគិតថ្លៃជូនពលរដ្ឋដោយគ្មានការរើសអើង មានថ្នាំព្យាបាលគ្រប់គ្រាន់ និងការព្យាបាលជម្ងឺដែលមានគុណភាព

៧- ទទួលបាន**ឱកាសដូចគ្នាក្នុងការអប់រំ** ជួយជំរុញឱ្យកុមារបានចូលរៀនគ្រប់ៗគ្នា និងអាចបន្តការសិក្សានេះដល់ឧត្តមសិក្សា។

ទីស្នាក់ការកណ្តាល: ផ្ទះលេខ ២០៩ ផ្លូវអូរអំបិល សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters: House #209, National Road Aurambel, Sangkat Veal Sbov, Khan Chbar Ampov, Phnom Penh, Kingdom of Cambodia
Email: info@candlelightparty.org

# តើមូលហេតុអ្វី ទើបបានជា គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ចាំបាច់ដាក់សកម្មជន របស់ខ្លួន ចូលរួមឈរឈ្មោះជាបេក្ខភាពមេឃុំ ឬចៅសង្កាត់ ក្នុងអាណត្តិទី៥នេះ

សំណួរទាំងអស់នេះ គឺតែងតែជាការចង់ដឹងពីសំណាក់បងប្អូនជនរួមជាតិជាទីគោរព និងជាទីស្រឡាញ់គ្រប់រូប ដោយទាំងអស់គ្នាបានដឹងយ៉ាងច្បាស់ហើយថា **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** សម្រាប់ការគាំទ្រ គឺនៅមានចំនួនតិចតួចនៅឡើយ

ដាក់ស្តែងថ្នាក់ដឹកនាំដែលជាក្បាលម៉ាស៊ីនរបស់គណបក្សមួយនេះ គឺនៅមាន សភាពក្មេងខ្ចីក្នុងវិស័យនយោបាយ ហើយចំនួនសមាជិកគាំទ្រក៏នៅមានចំនួនតិចផងដែរ ។ បងប្អូនប្រជាពលរដ្ឋជាច្រើន តែងស្តែងចេញនូវមតិផ្ទាល់ខ្លួនថា **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** ដាក់សកម្មជនរបស់ខ្លួនអោយឈរឈ្មោះជាបេក្ខភាពមេឃុំ ឬចៅសង្កាត់ គឺគ្រាន់តែជាការល្បងមើលប៉ុណ្ណោះ ហើយក៏គ្មានសង្ឃឹមថា អាចនឹងឈ្នះគណបក្សនយោបាយ ធំៗ ដែលគេមានទាំងសេដ្ឋកិច្ច និងចំនួនការគាំទ្រ របស់គេ ច្រើន នោះឡើយ ។

## គោលនយោបាយគណបក្ស

១. ប្តេជ្ញា: បំបាត់ការរើសអើង ក្នុងមូលដ្ឋាន ឃុំ-សង្កាត់ ។

២. ប្តេជ្ញា: បំបាត់អំពើពុករលួយក្នុងមូលដ្ឋាន ឃុំ-សង្កាត់ ។

៣. ប្តេជ្ញា: គាំទ្រគម្រោង នៃកញ្ចប់ថវិកាជាតិ អភិវឌ្ឍន៍ក្នុងមូលដ្ឋាន ។

៤. ប្តេជ្ញា: ប្តេជ្ញាបង្កើតទីផ្សារក្នុងសហគមន៍ ធានាតម្លៃ លើស្ថានភាព កសិផលមូលដ្ឋាន ។

៥. ប្តេជ្ញា: លើកកម្ពស់ស្ត្រី (យេនឌ័រ)ក្នុងការបញ្ចេញមតិ ក្នុងសង្គមសេដ្ឋកិច្ច ។

៦. ប្តេជ្ញា: កោះប្រជុំ និងផ្តល់របាយការណ៍ ស្តីពី ការអភិវឌ្ឍន៍ រួមទាំងដំណោះស្រាយប្រចាំខែ ។

៨. ប្តេជ្ញា: ទទួលខុសត្រូវ ខ្ពស់ ចំពោះការចុះហត្ថលេខា លើឯកសារការងាររដ្ឋបាល ។

# ការប្តេជ្ញា របស់ បេក្ខភាពមេឃុំ ឬ ចៅសង្កាត់នៃគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច

**គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** មានទិសដៅ និង ចក្ខុវិស័យយ៉ាងច្បាស់លាស់បំផុត ទើបសម្រេចចាត់តាំងសកម្មជនរបស់ខ្លួនអោយឈរឈ្មោះជាបេក្ខភាពមេឃុំ ឬ ចៅសង្កាត់ ក្នុងអាណត្តិ ទី៥ នេះ ហើយដាក់ស្តែងការចាត់តាំងសមាជិកខ្លួននេះគឺពុំមែនជាសកម្មភាពគ្រាន់តែជាការល្បងមើល ដូចការយល់ឃើញរបស់បងប្អូន ពលរដ្ឋមួយចំនួននោះឡើយ ព្រោះ ជាការពិតប្រាកដនៃដង្ហើមហារីក ទំនាស់រឿងរ៉ាវដីធ្លីរ៉ាវ៉ែរ គឺភាគច្រើនណាស់ដែលកើតចេញពីការធ្វេសប្រហែសថ្នាក់ដឹកនាំមូលដ្ឋាន ដែលកន្លងមកធ្លាប់ធ្វើអោយពលរដ្ឋរងទុក្ខគ្មានល្ហែ ។

ដើម្បីជាមធ្យោបាយដ៏ល្អបំផុតក្នុងការចូលរួមចំណែកជួយប្រជាពលរដ្ឋបាន **គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** បានកំណត់ជំរុញអោយសមាជិកខ្លួន ត្រូវតែឈរឈ្មោះជាបេក្ខភាពមេឃុំ ឬ ចៅសង្កាត់តាមយុទ្ធសាស្ត្រដែលបានគ្រោងទុក។

ទោះបីជាសម្លេងការគាំទ្ររបស់បងប្អូន មានចំនួនតិចឬក៏ច្រើនក្តី ប៉ុន្តែបេក្ខភាពមេឃុំ ឬ ចៅសង្កាត់នៃ**គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** ម្នាក់ៗសុទ្ធសឹងតែធ្វើការប្តេជ្ញាខ្ពស់ ថាចាំបាច់ត្រូវតែប្រើសមត្ថភាព របស់ខ្លួនបម្រើសេចក្តីត្រូវការរបស់បងប្អូនគ្រប់រូបអោយបាន ។

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ

នរោត្តម សីហមុនី

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**ផ្ញើជូនជនរួមជាតិ បងប្អូន កូនក្មួយ ជាទីគោរពស្នេហាដ៏ជ្រាលជ្រៅបំផុត**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ។ ក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវជាឱឡារិក ជូនជនរួមជាតិ បងប្អូន កូនក្មួយ អ្នកបោះឆ្នោតទាំងអស់ សូមមេត្តាអញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ។

ការបោះឆ្នោតនៅថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ គឺជាការបោះឆ្នោតជាទូទៅ ជាសកល ដោយសម្ងាត់ តាមលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដូចនេះសុំកុំឱ្យមានការព្រួយបារម្ភពីការគាបសង្កត់ ការគំរាមកំហែង ឬសម្លុតពីជនណាម្នាក់ ឬគណបក្សណាមួយឱ្យសោះ ។

ខ្ញុំសូមបងប្អូន កូនក្មួយ មេត្តាប្រើសិទ្ធិសេរីភាពរបស់ខ្លួន បោះឆ្នោតទៅតាមសតិសម្បជញ្ញៈរបស់ខ្លួនម្នាក់ៗ ដែលមានទំនុកចិត្តទៅលើបេក្ខជន ឬគណបក្សនយោបាយណាមួយ។

សូមបងប្អូន កូនក្មួយ ជនរួមជាតិទាំងអស់ ប្រកបនូវព្រះពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងមេត្តាទទួលនូវសេចក្តីគោរពស្នេហាដ៏ជ្រាលជ្រៅជាទីបំផុត អំពីខ្ញុំ។

ន សីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ** : ០០១ **គ.ជ.ប**.ស.ល.រ

# សេចក្តីអំពាវនាវ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ ចាប់ផ្តើមពីម៉ោង ៧:០០ព្រឹក រហូតដល់ម៉ោង ៣:០០រសៀល។ ការបោះឆ្នោតនេះកាន់តែខិតជិតមកដល់ហើយ ហេតុនេះ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមអំពាវនាវដូចតទៅ៖

- សូមប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២១ ទាំងអស់ត្រៀមខ្លួន និងត្រៀមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ដើម្បីចូលរួមបោះឆ្នោត នៅថ្ងៃបោះឆ្នោតឱ្យបានគ្រប់ៗគ្នា
- ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២១ ដែលបានប្រើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ហើយមិនទាន់មាន អ.ខ ឬ អ.ខ បានអស់សុពលភាព ឬមិនទាន់ទទួលបាន ឬបាត់ ឬខូច ឬកែតម្រូវ សូមប្រញាប់រួសរាន់ទៅស្នើសុំ ឯ.អ ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងអាជ្ញាធរឃុំ សង្កាត់នៃឃុំ សង្កាត់ ដែលខ្លួនត្រូវទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា
- ការចេញ ឯ.អ ចាប់ផ្តើមពីថ្ងៃទី៥ ខែឧសភា នឹងត្រូវបញ្ឈប់នៅថ្ងៃសុក្រ ទី៣ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៥:៣០នាទីល្ងាច
- ប្រធានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មេឃុំ ចៅសង្កាត់ និងមេភូមិត្រូវធ្វើការផ្សព្វផ្សាយសេចក្តីអំពាវនាវនេះឱ្យបានទូលំទូលាយ ដើម្បីជំរុញឱ្យប្រជាពលរដ្ឋមកស្នើសុំ ឯ.អ បានទាន់ពេលវេលា ដោយឥតបង់ថ្លៃ។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សង្ឃឹមយ៉ាងមុតមាំថា គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមេឃុំ ចៅសង្កាត់ នឹងយកចិត្តទុកដាក់ជំរុញ និងពង្រឹងការចេញ ឯ.អ ជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន៕

ថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

ប្រាជ្ញ ចន្ទ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ: ០០២ គ.ជ.ប.ស.ក.វ

# សេចក្តីអំពាវនាវ

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដល់អ្នកបោះឆ្នោត។ ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។

នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលមានរយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី២១ ខែឧសភា រហូតដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សូមអំពាវនាវដល់គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រនៃគណបក្សនយោបាយទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គោរពតាមបទបញ្ជា និងនីតិវិធី ក្រមសីលធម៌ និងគោលការណ៍នានាដែលបានកំណត់ដោយ គ.ជ.ប ដើម្បីឱ្យការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយប្រព្រឹត្តទៅដោយសន្តិវិធី អហិង្សា សន្តិសុខ និងសុវត្ថិភាព។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សូមអំពាវនាវដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងក្នុងសកម្មភាពការងាររបស់ខ្លួន និងត្រូវសម្របសម្រួល ទីកន្លែង ផ្លូវ ពេលវេលា ដើម្បីឱ្យគណបក្សនយោបាយនីមួយៗ អាចអនុវត្តកម្មវិធីឃោសនាបោះឆ្នោត និងការហែក្បួនឃោសនាបោះឆ្នោតរបស់ខ្លួនប្រព្រឹត្តទៅដោយស្មើភាពគ្នា។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សង្ឃឹមយ៉ាងមុតមាំថា បណ្តាគណបក្សនយោបាយ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធនឹងចូលរួមសហការតាមការអំពាវនាវក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដោយគោរពច្បាប់ជាធរមាន ដើម្បីឱ្យការឃោសនាបោះឆ្នោតនេះ ប្រព្រឹត្តទៅដោយរលូន និងធានាបាននូវសិទ្ធិគណបក្សនយោបាយ និងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។៚

ថ្ងៃអង្គារ ៧កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

គ.ជ.ប

# គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

## ថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២

| | |
|---|---|
| គណបក្សប្រជាជនកម្ពុជា<br>ប្រ.ជ | គណបក្សកម្ពុជានិយម<br>ប.ក |
| គណបក្ស ភ្លើងទៀន<br>គ.ភ.ទ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន<br>គ.ប.ម |
| គណបក្សហ្វ៊ុនស៊ិនប៉ិច<br>រ.រ.ជ.ក.ឯ.អ.ស.ស | គណបក្សខ្មែររួបរួម<br>គ.ខ.ម |
| គណបក្ស ខ្មែររួបរួមជាតិ<br>ខ.រ.ជ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ<br>គ.ស.ស.ប |
| គណបក្សខ្មែរស្រឡាញ់ជាតិ<br>គ.ខ.ស.ជ | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា<br>គ.ជ.ប.ក |
| គណបក្សសញ្ជាតិកម្ពុជា<br>គ.ស.ក | គណបក្សឯកភាពជាតិខ្មែរ<br>គ.ឯ.ជ |
| គណបក្សយុវជនកម្ពុជា<br>គ.យ.ក | គណបក្សរស្មីខេមរា<br>គ.រ.ខ |
| គណបក្សកែទម្រង់កម្ពុជា<br>គ.ក.ក | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច<br>គ.ខ.អ.ស |
| គណបក្សឆន្ទៈខ្មែរ<br>គ.ឆ.ខ | |

**កំណត់សម្គាល់ ៖ នេះមិនមែនជាសន្លឹកឆ្នោតទេ**